# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូប្រសូតនៅព្រះសហគមន៍សន្តយ៉ូសែប
# ផ្សារតូច ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩
## សញ្ញាសម្គាល់នៃព្រះយេស៊ូយាងមក

**អត្ថបទទី១៖ អេសាយ ៩,១-៦**

ប្រជាជនដែលដើរក្នុងភាពងងឹត បានឃើញពន្លឺមួយដ៏ចិញ្ចែងចិញ្ចាច មានពន្លឺមួយលេចឡើងបំភ្លឺអស់អ្នក ដែលរស់នៅក្រោមអំណាចនៃសេចក្តីស្លាប់។ អស ៩,១

**អត្ថបទទី២៖ ទីតុស ២,១១-១៤**

ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យប្រណីសន្តោសមក ដើម្បីសង្គ្រោះមនុស្សទាំងអស់។ ទត ២,១១

**ដំណឹងល្អ៖ លូកា ២,១-១៤**

នេះជាសញ្ញាសម្គាល់ឲ្យអ្នករាល់គ្នាដឹង គឺអ្នករាល់គ្នាមុខជាឃើញទារកមួយ ទើបនឹងប្រសូត រុំដោយសំពត់ ផ្ដេកនៅក្នុងស្នូកសត្វ។ លក ២,១២

បងប្អូនជាទីស្រឡាញ់!

រីករាយបុណ្យព្រះយេស៊ូប្រសូត នេះជាអំណរសប្បាយសម្រាប់យើងទាំងអស់គ្នាដែលជួបជុំគ្នានៅក្នុងយប់ដ៏សុខសាន្តនេះ ដើម្បីអរព្រះគុណព្រះជាម្ចាស់ដែលបានណែនាំព្រះយេស៊ូប្រសូតសម្រាប់បំភ្លឺយើងទាំងអស់នៅក្នុងពិភពលោកទាំងមូល។ នៅបុណ្យព្រះយេស៊ូប្រសូត អំណោយដែលយើងទទួលដ៏ពិសេសបំផុតគឺព្រះយេស៊ូផ្ទាល់ ព្រះជាម្ចាស់មានកាដូមួយយ៉ាងអស្ចារ្យ "**ព្រះបន្ទូលព្រះអង្គចាប់កំណើតជាមនុស្ស**"។ យើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជារៀងរាល់ពេល យើងដឹងថានៅរាត្រីដែលព្រះយេស៊ូប្រសូត គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ទាល់ដែលចាប់កំណើតជាមនុស្ស។ រួមជាមួយទេវទូតទាំងឡាយ យើងបានច្រៀងកោតសរសើរសិរីរុងរឿងរបស់ព្រះជាម្ចាស់ យើងពោរពេញដោយអំណរសប្បាយដោយសារយើងដឹងថា យប់នេះយើងមានព្រះសង្គ្រោះដែលប្រសូតដើម្បីសង្គ្រោះយើង។ ព្រះសង្គ្រោះយាងមក ដើម្បីឲ្យយើងទាំងអស់ពោរពេញដោយសេចក្តីសុខសាន្ត យើងពោរពេញដោយអំណរសប្បាយ។ អំណរសប្បាយដែលយើងទទួលយប់នេះ ដូចគ្រូគង្វាលបានស្តាប់អំណរសប្បាយពីទេវទូត **តើអំណរសប្បាយដែលគ្រូគង្វាលបានទទួល២,០០០ឆ្នាំមុន សម្រាប់យើងនៅឆ្នាំ២,០២០នេះយើងទៅចែករំលែកអំណរសប្បាយនេះទៅនរណា?** ដូចហោរាចារ្យដែលបានមកថ្វាយបង្គំព្រះកុមារយេស៊ូ **តើយើងទៅថ្វាយបង្គំដល់ព្រះយេស៊ូរបៀបណានៅឆ្នាំ២,០១៩-២,០២០នេះ?**

២,០០០ឆ្នាំមុន ព្រះយេស៊ូបានកើតនៅភូមិបេថ្លេហិមដែលជាភូមិដ៏តូចមួយ ជាភូមិដែលមានប្រជាជនរស់នៅតិច ជាភូមិដែលនៅឆ្ងាយពីស្រុកកំណើតរបស់ឪពុកម្តាយព្រះយេស៊ូ។

ដំណើរនៃជីវិតរបស់ព្រះយេស៊ូ បានចាប់ផ្ដើមពិបាកណាស់ឪពុកម្ដាយត្រូវការធ្វើដំណើរយ៉ាងឆ្ងាយ ដោយសារថ្ងៃដែលព្រះយេស៊ូប្រសូតជាថ្ងៃដែលចៅអធិរាជរ៉ូម៉ាំងធ្វើជំរឿនប្រជាជន។ ព្រះនាងម៉ារីមានផ្ទៃពោះ ដល់ពេលវេលាប្រសូតបុត្រតែត្រូវធ្វើដំណើរយ៉ាងពិបាក ដល់ម៉ោងដែលព្រះនាងម៉ារីឈឺពោះជាពេលវេលាពិបាកថែមទៀត លោកយ៉ូសែបបានខិតខំស្វែងរកផ្ទះសំណាក់តែគេបានបដិសេធដោយសារគ្មានកន្លែងទំនេរ។ ហោរាចារ្យដែលបានទៅគាល់ស្ដេចហេរ៉ូតដើម្បីសួររកទីតាំងដែលព្រះយេស៊ូបានប្រសូត នៅពេលនោះស្ដេចហេរ៉ូតបានបង្កើតគម្រោងការមួយអាក្រក់ណាស់ ដោយសម្លាប់កូនក្មេងដែលទើបនឹងកើតទាំងអស់ព្រោះសង្ឃឹមថានៅក្នុងចំណោមកូនក្មេងទាំងនោះមានព្រះយេស៊ូដែរ។ គាត់បារម្ភថា នៅថ្ងៃអនាគតព្រះយេស៊ូនឹងសោយរាជ្យជំនួសគាត់និងអង្គុយលើបល្ល័ង្ករបស់គាត់។ នៅពេលព្រះយេស៊ូប្រសូត ពិភពលោកនេះអំពើអាក្រក់ទាំងអស់ព្យាយាមចេញកម្លាំងដល់កំពូលដើម្បីប្រចាំងព្រះអង្គ ក៏ប៉ុន្តែបទចម្រៀងរបស់ទេវទូតទៅជាសម្លេងមួយដែលចេញពីភាពងងឹត ដើម្បីណែនាំឲ្យមនុស្សទាំងអស់ពោរពេញដោយភាពកក់ក្ដៅ។ គេបានលឺព្រះសូរសៀងតាមរយៈទេវទូតថា យប់នេះព្រះសង្គ្រោះនឹងប្រសូតហើយ ណែនាំឲ្យយើងទាំងអស់ពោរពេញដោយសេចក្ដីសុខសាន្ត ពោរពេញដោយអំណរសប្បាយ ពោរពេញដោយសេចក្ដីសង្ឃឹម។

យប់នោះ មានផ្កាយដែលបានណែនាំឲ្យហោរាចារ្យធ្វើដំណើរពីចម្ងាយ ផ្កាយដែលណែនាំឲ្យហោរាចារ្យដឹងពីទីតាំងដែលមានព្រះសង្គ្រោះប្រសូត ផ្កាយនេះទៅជាពន្លឺដ៏ត្រចះត្រចង់នៅក្នុងភាពងងឹតនៃការស្អប់គ្នា នៃអំពើអាក្រក់ដែលកំពុងកើតឡើងពេលព្រះយេស៊ូប្រសូត។ នៅពេលព្រះយេស៊ូសោយទិវង្គត ព្រះជាម្ចាស់បានចូលនៅក្នុងគម្រោងការដ៏ពិសេសរបស់ព្រះអង្គដោយណែនាំឲ្យព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង និងណែនាំឲ្យយើងទាំងអស់ចូលនៅក្នុងពន្លឺរបស់ព្រះគ្រីស្ដអស់កល្បជានិច្ច។ ដូច្នេះ យប់នេះយើងត្រូវការសួរខ្លួនឯងថា **តើខ្ញុំណែនាំដំណឹងល្អអំពីព្រះយេស៊ូប្រសូតដល់នរណា? តើខ្ញុំទៅថ្វាយបង្គំជាមួយនរណា ដើម្បីឲ្យព្រះយេស៊ូទទួលសេចក្ដីសុខនៅយប់ដ៏សុខសាន្តនេះ?** ក្នុងរយៈពេលមួយខែក្នុងរដូវអបអរសាទរព្រះយេស៊ូប្រសូតនេះ ខ្ញុំនឹងជួបមនុស្សជាង១៥,០០០នាក់ មានកូនក្មេង មានប្រជាជន មានមនុស្សចាស់ មានអ្នកជាប់នៅមន្ទីរឃុំឃាំង មានគ្រីស្ដបរិស័ទតាមព្រះសហគមន៍ដែលខ្ញុំនឹងទៅ មានពុទ្ធបរិស័ទ...។ នេះជាអ្វីដែលខ្ញុំបានឃើញ និងជាអ្វីដែលយើងបានចែករំលែកអស់ពីសមត្ថភាព ខ្ញុំសូមអរគុណដល់ព្រះសហគមន៍ទូទាំងភូមិភាគភ្នំពេញ តាមកន្លែងនីមួយៗបានយកចិត្តទុកដាក់រៀបចំទទួលព្រះយេស៊ូប្រសូត ដើម្បីចែករំលែកជាមួយមនុស្សទូទៅដោយមិនគិតតែគ្នាយើង។ យើងណែនាំឲ្យប្រជាជនមួយចំនួនទាំងនៅទីក្រុង ទាំងនៅជបបទ បានស្ដាប់ឮដំណឹងល្អថា ព្រះយេស៊ូប្រសូតហើយ។

ទេវទូតបាននិយាយទៅគ្រូគង្វាល យើងមានសញ្ញាមួយដែលបញ្ជាក់ថាព្រះយេស៊ូប្រសូតហើយ គឺមានកូនង៉ែតមួយរូបប្រសូតនៅក្រោលគោ **តើយើងមានសញ្ញាអ្វីខ្លះដែលណែនាំឲ្យយើងមើលឃើញវត្តមានរបស់ព្រះយេស៊ូ ដែលកំពុងប្រសូតនៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ?** ខ្ញុំមានសញ្ញាប្រាំដែលខ្ញុំបានឃើញជាក់ស្តែង ណែនាំឲ្យខ្ញុំអរព្រះគុណព្រះជាម្ចាស់ដោយដឹងថាពិតមែនព្រះយេស៊ូដែលកំពុងប្រសូតនៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះគឺ៖

**សញ្ញាទីមួយ** ពីរបីសប្តាហ៍មុនមានទេសរដ្ឋមន្ត្រីទៅសួរសុខទុក្ខនៅវត្តអង្គមន្ត្រីខេត្តតាកែវ ពេលចប់កម្មវិធីនៅវត្តឯកឧត្តមនិងលោកជំទាវ បានទៅសួរសុខទុក្ខដល់ភូមិសិប្បកម្មរបស់យើង ដោយគ្មាននៅក្នុងគម្រោងការរបស់គាត់ទេ។ គាត់បានមើលកូនស្រីពិការកំពុងកាត់ដេរសម្លៀកបំពាក់ មើលយុវជនពិការកំពុងធ្វើស្គរគ្រាប់ មើលយុវនារីនិងស្ត្រីកំសត់កំពុងត្បាញសូត្រនិងអំបោះ មើលយុវជនពិការធ្វើជាងទង មើលយុវនារីធ្វើស្បែកជើងស្រកីដូង មើលយុវជនយុវនារីធ្វើនំធ្វើសាប៊ូ...។ ឯឧត្តមនិងលោកជំទាវ បានសួរសុខទុក្ខពួកគេពេញមួយម៉ោង ពីរថ្ងៃក្រោយមកឯកឧត្តមបានផុសក្នុងហ្វេសបុកផ្ទាល់ខ្លួនថា **"ខ្ញុំនិងភរិយារបស់ខ្ញុំ បានទៅមើលភូមិសិប្បកម្មដ៏ពិសេស បង្កើតដោយលោកអូលីវីយេ និងព្រះសហគមន៍កាតូលិកកម្ពុជា។ ខ្ញុំនិងភរិយាខ្ញុំរំភើបមែនទែន ពេលឃើញកូនក្មេងពិការ ឃើញយុវជនយុវនារីដែលគ្មានទីពឹង មានការងារធ្វើនិងបានចូលនៅក្នុងសង្គមដ៏ពេញលក្ខណៈ"**។ របៀបដែលឯកឧត្តមនិងលោកជំទាវ បានយកចិត្តទុកដាក់ដើម្បីចូលនៅក្នុងគម្រោងការបរិយាបន គឺណែនាំឲ្យមនុស្សទាំងអស់ចូលនៅក្នុងសង្គមបច្ចុប្បន្ននេះ ពិការក្តី កំសត់ទុរគតក្តី ក្រីក្រក្តី អាចមានសមត្ថភាពដើម្បីរីកចម្រើននិងចិញ្ចឹមជីវិតផ្ទាល់ខ្លួន។ នេះជាសញ្ញាសម្គាល់នៃព្រះយេស៊ូយាងមក ព្រះយេស៊ូណែនាំឲ្យយើងចាប់អារម្មណ៍អំពីបងប្អូនឯទៀតៗ ជាពិសេសអ្នកតូចតាចដើម្បីចូលនៅក្នុងសង្គមដ៏ពេញលក្ខណៈ។

**សញ្ញាទីពីរ** ប៉ុន្មានថ្ងៃមុនខ្ញុំជិះកង់ នៅផ្លូវហាណូយខ្ញុំបានឃើញប៉ូលីសដើរលក់ស្ពៃជូរនិងត្រសក់ជ្រក់នៅពេលមានភ្លើងស្តុប។ ខ្ញុំបានឃើញនៅក្បែរនោះមានយាយម្នាក់ ដែលជាអ្នកលក់ស្ពៃជូរនិងត្រសក់ជ្រក់នេះតែគាត់គ្មានកម្លាំង លោកប៉ូលីសនេះគាត់បានជួយលក់លោកយាយ។ នេះជាសញ្ញាសម្គាល់នៃបុណ្យព្រះយេស៊ូប្រសូត ជួយគ្នាទៅវិញទៅមកតាមសមត្ថភាពដែលយើងមាន ឲ្យយើងចេះបើកភ្នែកដើម្បីជួយគ្នា។

**សញ្ញាទីបី** ខ្ញុំបានទៅផ្សារទំនើបអ៊ីអនសែនសុខពីរថ្ងៃមុន ខ្ញុំបានឃើញនៅជាន់ក្រោមមានគ្រែពេទ្យ២០គ្រែ មានពេទ្យជាង២០នាក់ និងមានអ្នកដេកលើគ្រែនោះដើម្បីបរិច្ចាគឈាមជួយជីវិត។ នៅពេលយើងឃើញបែបនេះ នៅកន្លែងទំនើបដែលសម្បូរដោយអ្នកមាន នៅមុខគេគេហ៊ានផ្តល់ឈាមរបស់ខ្លួនដើម្បីសង្គ្រោះជីវិតមនុស្ស នេះជាវត្តមានរបស់ព្រះយេស៊ូដែលកំពុងប្រសូតឲ្យយើងចេះចែករំលែកអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់យើង។

**សញ្ញាទីបួន** នៅព្រះសហគមន៍សន្តីម៉ារីញញឹម ជារៀងរាល់ឆ្នាំមានគណៈកម្មការវត្ត និងព្រះសង្ឃ មកសួរសុខទុក្ខនិងជូនពរបុណ្យព្រះយេស៊ូប្រសូតដល់ព្រះសហគមន៍កាតូលិក។ ឆ្នាំនេះ ចៅអធិការវត្តបានជូនខ្ញុំនូវព្រះពុទ្ធរូបដែលមកពីប្រទេសឥណ្ឌា ដោយមានសង្ឃដីកាថា "**នេះមិនសូវមានតម្លៃទេ ប៉ុន្តែអាត្មាចង់បង្ហាញអំពីមិត្តភាពដែលយើងមានរវាងលោកឪពុកនិងអាត្មា និងរវាងព្រះសហគមន៍កាតូលិកនិងពុទ្ធសាសនា**"។ នេះជាសញ្ញាមួយនៃការសន្ទនា ទំនាក់ទំនងដែលយើងមាន ខ្ញុំគិតថាព្រះយេស៊ូបានណែនាំឲ្យយើងបង្កើតទំនាក់ទំនងនៅក្នុងការសន្ទនាដើម្បីយល់ចិត្តគ្នានិងធ្វើដំណើរជាមួយគ្នានៅក្នុងសង្គមបច្ចុប្បន្ននេះ។

**សញ្ញាទីប្រាំ** អភិបូជាសម្រាប់បុណ្យព្រះយេស៊ូបីកន្លែងដែលខ្ញុំបានថ្វាយ ខ្ញុំបានឃើញគ្រីស្តបរិស័ទមួយចំនួនដែលមិនបានចូលព្រះវិហារយូរហើយ នៅយប់ព្រះយេស៊ូប្រសូតគេបានមកចូលរួម។ ក្នុងឱកាសបុណ្យព្រះយេស៊ូឆ្នាំនេះ គាត់យល់ថាព្រះយេស៊ូយាងមកដើម្បីលើកលែងទោសឲ្យយើង យើងធ្វើដូចម្តេចដើម្បីលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ គេបានមកចូលរួមពោរពេញដោយអំណរសប្បាយ ដោយចូលអភិបូជា ថ្វាយបង្គំនៅរោងព្រះយេស៊ូប្រសូត សួរសុខទុក្ខគ្នាទៅវិញទៅមក។ នេះជាព្រះយេស៊ូដែលកំពុងធ្វើការនៅក្នុងដួងចិត្តគេ នេះជាព្រះយេស៊ូដែលកំពុងប្រសូតនៅក្នុងដួងចិត្តរបស់គេ ពិតមែនដោយសារព្រះយេស៊ូណែនាំឲ្យយើងសម្រុះសម្រួលគ្នាដើម្បីទៅជាបងប្អូនសាជាថ្មី។ ជួនកាលយើងអន់ចិត្តនឹងព្រះសហគមន៍ អន់ចិត្តជាមួយលោកអភិបាល អន់ចិត្តនឹងលោកបូជាចារ្យ អន់ចិត្តជាមួយបងប្រុសបងស្រី អន់ចិត្តនឹងគ្រីស្តបរិស័ទ ប៉ុន្តែសំខាន់គឺព្រះយេស៊ូណែនាំឲ្យយើងសម្រុះសម្រួលគ្នា ដើម្បីទៅជាបងប្អូននឹងគ្នាសាជាថ្មីនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

ខ្ញុំអធិដ្ឋានសម្រាប់បងប្អូន ឲ្យរស់នៅក្នុងអំណរសប្បាយក្នុងឆ្នាំថ្មីនេះ ឲ្យយើងទទួលព្រះពន្លឺពីព្រះយេស៊ូប្រសូតដើម្បីចែករំលែកជាមួយបងប្អូនយ៉ាងច្រើន នៅក្នុងព្រះសហគមន៍ក្តី នៅក្នុងសង្គមក្តី ដោយដឹងថាមានតែព្រះគ្រីស្តដែលជាព្រះពន្លឺ មានតែព្រះគ្រីស្តដែលអាចបំភ្លឺពិភពលោកទាំងមូលបាន។ អបអរសាទរបុណ្យព្រះយេស៊ូប្រសូត! អាម៉ែន៕